**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ១០២០ សហវ.ប្រក

# ប្រកាស

## ស្តីពី

## ការរៀបចំ និងការប្រព្រឹត្តិទៅនៃនាយកដ្ឋានព័ត៌មានវិទ្យា នៃអគ្គនាយកដ្ឋានរតនាគារជាតិនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

***

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការបំពេញបន្ថែម និងកែសំរួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០០៣ ស្តីពីការបង្កើតនាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៨២/អនក្រ/បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ មិនា ឆ្នាំ ២០០៨ ស្តីពីការបំពេញបន្ថែមនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតម្លើងទីចាត់ការគយនិងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យទៅជាអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- តាមតំរូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**សម្រេច**

**ប្រការ ១:** នាយកដ្ឋានព័ត៌មានវិទ្យា នៃអគ្គនាយកដ្ឋានរតនាគារជាតិ មានភារកិច្ច ដូចមានចែងក្នុង មាត្រា ៣០ នៃអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨:

-អភិវឌ្ឍយុទ្ធសាស្ត្រ និងគ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យានៅថ្នាក់កណ្តាល និងថ្នាក់មូលដ្ឋាន

-កសាងគោលនយោបាយ និងនីតិវិធីព័ត៌មានវិទ្យា

-រៀបចំ ថែរក្សាប្រព័ន្ធត្រួតពិនិត្យ និងប្រព័ន្ធសុវត្ថិភាព ផ្នែកព័ត៌មានវិទ្យា

-គ្រប់គ្រងកិច្ចសន្យាដែលបានធ្វើជាមួយអ្នកផ្តល់សេវា ឬអ្នកផ្គត់ផ្គង់

-វិភាគមុខងារ និងតំរូវការតាមនាយកដ្ឋាននិមួយៗ

-រៀបចំរបាយការណ៍ និងតាមដានការអនុវត្តន៍កម្មវិធីស្តីពីព័ត៌មានវិទ្យា

-រៀបចំកម្មវិធី និងបណ្តុះបណ្តាលព័ត៌មានវិទ្យាដល់ថ្នាក់កណ្តាល និងថ្នាក់មូលដ្ឋាន។

**ប្រការ ២:** នាយកដ្ឋានព័ត៌មានវិទ្យា នៃអគ្គនាយកដ្ឋានរតនាគារជាតិ ដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួន ជាជំនួយការ។

**ប្រការ ៣:** រចនាសម្ព័ន្ធរបស់នាយកដ្ឋានព័ត៌មានវិទ្យា នៃអគ្គនាយកដ្ឋានរតនាគារជាតិ មានការិយាល័យចំនួន ០៣:

ក. ការិយាល័យព័ត៌មានវិទ្យាថ្នាក់កណ្តាល

ខ. ការិយាល័យព័ត៌មានវិទ្យាថ្នាក់មូលដ្ឋាន

គ. ការិយាល័យព័ត៌មានវិទ្យាសរុប

**ប្រការ ៤:** ភារកិច្ចរបស់ការិយាល័យព័ត៌មានវិទ្យាថ្នាក់កណ្តាល មានដូចខាងក្រោម:

- រៀបចំយុទ្ធសាស្ត្រគ្រប់គ្រងកិច្ចដំណើរការប្រព័ន្ធព័ត៌មានវិទ្យា នៅថ្នាក់កណ្តាល
- សិក្សាអំពីផែនការមេ សំរាប់ភ្ជាប់យុទ្ធសាស្ត្រក្នុងកិច្ចដំណើរការប្រព័ន្ធព័ត៌មានវិទ្យា នៅថ្នាក់កណ្តាល
- បែងចែកផែនការសកម្មភាពសំរាប់អនុវត្ត ទៅតាមបណ្តានាយកដ្ឋាននៃអគ្គនាយកដ្ឋានរតនាគារជាតិ
- រៀបចំយន្តការផ្ទេរទិន្នន័យពីថ្នាក់មូលដ្ឋាន មកថ្នាក់កណ្តាល
- រៀបចំបណ្តាញ (Network) ប្រព័ន្ធត្រួតពិនិត្យ និង សុវត្ថិភាព ព័ត៌មានវិទ្យានៅថ្នាក់កណ្តាល
- បង្កើត និងធ្វើបច្ចុប្បន្នភាពគេហទំព័ររបស់អគ្គនាយកដ្ឋានរតនាគារជាតិ
- បង្កើត និងបែងចែកសិទ្ធិនៃការប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យាសំរាប់នាយកដ្ឋាននីមួយៗ
- បណ្តុះបណ្តាលសមត្ថភាពប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យាសំរាប់គ្រប់គ្រងគណនេយ្យសាធារណៈនៅថ្នាក់កណ្តាល
- សិក្សាពីតំរូវការប្រព័ន្ធព័ត៌មានវិទ្យាតាមផ្នែកដែលពាក់ព័ន្ធ នៅថ្នាក់កណ្តាល
- តាមដានការអនុវត្តន៍កម្មវិធីព័ត៌មានវិទ្យា និងរៀបចំរបាយការណ៍ នៅថ្នាក់កណ្តាល
- ចូលរួមសហការរៀបចំសេចក្តីព្រាងច្បាប់សំរាប់ទូទាត់ថវិកាប្រចាំឆ្នាំ។

**ប្រការ ៥:** ភារកិច្ចរបស់ការិយាល័យព័ត៌មានវិទ្យាថ្នាក់មូលដ្ឋាន មានដូចខាងក្រោម:

- រៀបចំយុទ្ធសាស្ត្រគ្រប់គ្រងកិច្ចដំណើរការប្រព័ន្ធព័ត៌មានវិទ្យានៅថ្នាក់មូលដ្ឋាន

- រៀបចំបណ្តាញ (Network) ប្រព័ន្ធត្រួតពិនិត្យ និង សុវត្ថិភាព ព័ត៌មានវិទ្យានៅថ្នាក់មូលដ្ឋាន
- បណ្តុះបណ្តាលសមត្ថភាពប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យាសំរាប់គ្រប់គ្រងគណនេយ្យសាធារណៈនៅថ្នាក់មូលដ្ឋាន
- សិក្សាពីតំរូវការប្រព័ន្ធព័ត៌មានវិទ្យាតាមផ្នែកដែលពាក់ព័ន្ធ នៅថ្នាក់មូលដ្ឋាន
- តាមដានការអនុវត្តន៍កម្មវិធីព័ត៌មានវិទ្យា និងរៀបចំរបាយការណ៍ នៅថ្នាក់មូលដ្ឋាន
- បង្កើតយន្តការដើម្បីរៀបចំរបាយការណ៍តុល្យភាពថវិការដ្ឋ ថវិកាខេត្ត-ក្រុង ស្រុក-ខ័ណ្ឌ និង ថវិកាឃុំ-សង្កាត់ ដើម្បីបញ្ជូនមកថ្នាក់កណ្តាល
- ចូលរួមសហការរៀបចំសេចក្តីព្រាងច្បាប់សំរាប់ទូទាត់ថវិកាប្រចាំឆ្នាំ ។

**ប្រការ ៦**: ភារកិច្ចរបស់ការិយាល័យព័ត៌មានវិទ្យាសរុប មានដូចខាងក្រោម:

- គ្រប់គ្រងកិច្ចសន្យាជាមួយអ្នកផ្តល់សេវាព័ត៌មានវិទ្យា
- ធ្វើការវាយតំលៃទៅលើកម្មវិធីព័ត៌មានវិទ្យា
- សហការជាមួយនាយកដ្ឋានព័ត៌មានវិទ្យានៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួង-ស្ថាប័នពាក់ព័ន្ធ
- រៀបចំរបាយការណ៍សរុបប្រចាំខែ-ឆ្នាំ ដែលបានមកពីការិយាល័យថ្នាក់កណ្តាល និង ថ្នាក់មូលដ្ឋាន
- ធ្វើស្ថិតិ និងរបាយការណ៍ចំណូល-ចំណាយថវិកាសរុបរបស់រតនាគារថ្នាក់កណ្តាល និងថ្នាក់មូលដ្ឋាន
- ចូលរួមសហការរៀបចំសេចក្តីព្រាងច្បាប់សំរាប់ទូទាត់ថវិកាប្រចាំឆ្នាំ ។

**ប្រការ ៧**: ភារកិច្ចទាំងឡាយណា ដែលមានការពាក់ព័ន្ធទៅនឹងសមត្ថកិច្ចរបស់នាយកដ្ឋាន ឬ អង្គភាពជំនាញដទៃ នៅក្រៅអគ្គនាយកដ្ឋានរតនាគារជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានរតនាគារជាតិ ត្រូវសហការជាមួយប្រធាននាយកដ្ឋាន ឬ អង្គភាពពាក់ព័ន្ធទាំងនោះ ដើម្បីស្នើសុំគោលការណ៍ពីថ្នាក់ដឹកនាំក្រសួងដោះស្រាយ ។

**មាត្រា ៨**: ប្រកាស ឬ លិខិតបទដ្ឋានទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៩**: អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានរតនាគារជាតិ ប្រធាននាយកដ្ឋានបុគ្គលិក និង អង្គភាពពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះ អោយមានប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី១៦ ខែតុលា ឆ្នាំ២០០៨

គាត ឈន់

**ចំលងជូន:**

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ទីស្តីការគណៈរដ្ឋមន្ត្រី
-រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
-ធនាគារជាតិនៃកម្ពុជា "ដើម្បីជូនជ្រាបជាព័ត៌មាន"
-ដូចប្រការ ៩ "ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ